ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១១២៧៤ អពដ

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧

# សេចក្ដីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ដែលកំពុងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាមេត្តាជ្រាបថា ការអនុវត្តបទប្បញ្ញត្តិនៃការផ្គត់ផ្គង់មិនជាប់អាករចំពោះសេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការ៤ នៃប្រកាសលេខ ៥៥៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ ត្រូវបានព្យួរការអនុវត្តជាបណ្ដោះអាសន្ន រហូតដល់មានការជូនដំណឹងជាថ្មី។

ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តកិច្ចសហប្រតិបត្តិការជាមួយផ្នែកឯកជន ដើម្បីពិនិត្យសិក្សាលម្អិតឡើងវិញនូវនិយមន័យនៃពាក្យ “សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ” និងការអនុវត្តអាករលើតម្លៃបន្ថែមលើសេវាមិនមែនជាមូលដ្ឋានខាងហិរញ្ញវត្ថុ ក្នុងគោលបំណងធានាបាននូវសង្គតិភាពក្នុងការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្ដីពីសារពើពន្ធ ព្រមទាំងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់ថា គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់នឹងសហការអនុវត្តតាមខ្លឹមសារនៃសេចក្ដីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh